ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៧ អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## ជូនទីស្តីការគណៈរដ្ឋមន្ត្រី

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា៤០ថ្មីនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/ នស/ ៩៤ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.៣០០ លានរៀល ( បួនពាន់បីរយលានរៀលគត់ ) ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច ) របស់ក្រសួង-ស្ថាប័នទាំងឡាយមានដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ក្រសួងព្រះបរមរាជវាំង | ចំនួន | ១០៧ លានរៀល |
| ២-អគ្គលេខាធិការដ្ឋានរដ្ឋសភា | ចំនួន | ៣០០ លានរៀល |
| ៣- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | ចំនួន | ១១ លានរៀល |
| ៤-ក្រសួងការពារជាតិ | ចំនួន | ៧០០ លានរៀល |
| ៥-ក្រសួងមហាផ្ទៃ ( ផ្នែកសន្តិសុខសាធារណៈ ) | ចំនួន | ៧៨ លានរៀល |
| ៦-ក្រសួងមហាផ្ទៃ ( ផ្នែករដ្ឋបាលទូទៅ ) | ចំនួន | ៣០០ លានរៀល |
| ៧-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច | ចំនួន | ៤៥ លានរៀល |
| ៨-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ចំនួន | ១៥០ លានរៀល |
| ៩-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ចំនួន | ៣០ លានរៀល |
| ១០-ក្រសួងពត៌មាន | ចំនួន | ៦០ លានរៀល |
| ១១-ក្រសួងសុខាភិបាល | ចំនួន | ៥០០ លានរៀល |
| ១២-ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ចំនួន | ៧០ លានរៀល |
| ១៣-ក្រសួងពាណិជ្ជកម្ម | ចំនួន | ២០ លានរៀល |
| ១៤-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | ចំនួន | ១០ លានរៀល |
| ១៥-ក្រសួងបរិស្ថាន | ចំនួន | ៥០ លានរៀល |
| ១៦-ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា | ចំនួន | ៤០ លានរៀល |
| ១៧-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំនួន | ១.០០០ លានរៀល |
| ១៨-ក្រសួងធម្មការ និង សាសនា | ចំនួន | ៣០ លានរៀល |
| ១៩-ក្រសួងកិច្ចការនារី | ចំនួន | ៣០ លានរៀល |
| ២០-ក្រសួងសាធារណការ និង ដឹកជញ្ជូន | ចំនួន | ៤០ លានរៀល |
| ២១-ក្រសួងទេសចរណ៍ | ចំនួន | ១៦៩ លានរៀល |
| ២២-ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ | ចំនួន | ១៥០ លានរៀល |
| ២៣-ក្រសួងធនធានទឹក និង ឧតុនិយម | ចំនួន | ៣៥០ លានរៀល |
| ២៤-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ចំនួន | ៣០ លានរៀល |
| ២៥-អាជ្ញាធរសេវាកម្មជាតិ | ចំនួន | ៣០ លានរៀល |

មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច ) ជូនទីស្តីការគណៈរដ្ឋមន្ត្រី ( គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ) សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ ។

<u>មាត្រា២</u>: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទិញប្រេងឥន្ធនៈ បូមទឹក គ្រោះរាំងស្ងួត ឆ្នាំ ២០០៤ ។

<u>មាត្រា៣</u>: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី . រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញកិច្ច . រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម. រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា. អគ្គលេខាធិការដ្ឋានរដ្ឋសភា. រដ្ឋមន្ត្រីក្រសួងការពារជាតិ. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ. រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច. រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ. រដ្ឋមន្ត្រីក្រសួងពត៌មាន. រដ្ឋមន្ត្រីក្រសួងសុខាភិបាល. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម. រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ. រដ្ឋមន្ត្រីក្រសួងបរិស្ថាន. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា. រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍. រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី. រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន. រដ្ឋមន្ត្រីក្រសួងទេសចរណ៍. រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់. ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត. អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្ដីជំរាបជូន

សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ